

ចុះសួរសុខទុក្ខអ្នកជាប់ពន្ធនាគារយ៉ាងទៀងទាត់ ដើម្បីជួយធ្វើយ៉ាងណាឱ្យអ្នកទាំងនោះ ទទួលបាននូវការប្រព្រឹត្តមួយចំពោះខ្លួន ដែលអាចទទួលយកបាន និងជួយការពារកុំឱ្យមានការបាត់ខ្លួន។

បេសកម្មរបស់ អាយ.ស៊ី.អរ.ស៊ី គឺការប្រតិបត្តិយ៉ាងមធ្យ័តប្រកបដោយភាពអព្យាក្រិត និង មិនលំអៀង ដើម្បីការពារ និង ជួយប្រជាពលរដ្ឋ ដែលរងគ្រោះដោយជម្លោះប្រដាប់អាវុធ និង អស្ថេរភាពផ្ទៃក្នុងនានា។

ក្នុងនោះរួមមាន :

- ចុះសួរសុខទុក្ខឈ្លើយសឹក និង ចំណាប់ខ្មាំងដែលជាប្រជាជនស៊ីវិល
- ស្រាវជ្រាវរកជនដែលបាត់ខ្លួន
- បញ្ជូនសាររវាងសមាជិកគ្រួសារដែលបែកបាក់គ្នា
- [illegible]ឱ្យគ្រួសារដែលបែកបាក់បានជួបជុំគ្នាវិញ
- ផ្តល់ជំនួយជាទឹកស្អាត អាហារ និងថ្នាំសង្កូវដល់អ្នកដែលត្រូវការ
- លើកកំពស់ការគោរពច្បាប់មនុស្សធម៌អន្តរជាតិ
- តាមដានការអនុវត្តន៍ច្បាប់មនុស្សធម៌អន្តរជាតិ
- រួមចំណែកអភិវឌ្ឍន៍ច្បាប់មនុស្សធម៌អន្តរជាតិ



ជួយឱ្យគ្រួសារដែលបែកបាក់ដោយសារអរិភាព និង ជម្លោះប្រដាប់អាវុធ បានជួបជុំគ្នាវិញ។

ចង់ស្វែងយល់បន្ថែម...

- សូមបើកមើលគេហទំព័រ WWW.ICRC.ORG
- ទំនាក់ទំនងប្រតិភូប្រចាំតំបន់របស់ អាយ.ស៊ី.អរ.ស៊ី ប្រចាំទីក្រុងបាងកក

អាសយដ្ឋាន
International Committee of the Red Cross
The Regional Delegation Bangkok
20 Sukhumvit Soi 4, Klongtoey
Bangkok 10110
Tel : +66 2251 0424
Fax : +66 2253 5428
E-mail: bangkok.ban@icrc.org

0728/303T 11/2007 5.000

ICRC



# អាយ.ស៊ី.អរ.ស៊ី

## ក្នុងសកម្មភាពជាក់ស្តែង

ICRC

# ICRC តើ អាយ.ស៊ី.អរ.ស៊ី ជាអ្នកណា?



មិនថាតាមរយៈវត្តផ្សព្វផ្សាយផ្លូវការ ឬ នៅតាមប៉ុស្តិ៍ត្រួតពិនិត្យយោធាឡើយ អាយ.ស៊ី.អរ.ស៊ី គ្រើនរំលឹកភាគីដែលកំពុងមានជម្លោះ ឬ ភាគីដែលបម្រុងមានជម្លោះអំពីសិទ្ធិ និង កាតព្វកិច្ចរបស់គូភាគីជម្លោះ ដែលមានចែងក្នុងច្បាប់មនុស្សធម៌អន្តរជាតិ ។ នោះហើយជាសកម្មភាពមួយដ៏សំខាន់របស់ អាយ.ស៊ី.អរ.ស៊ី ក្នុងចំណោមសកម្មភាពចម្បងជាច្រើន នៅទូទាំងពិភពលោក ។

គណៈកម្មាធិការអន្តរជាតិកាកបាទក្រហម (ICRC) ត្រូវបានបង្កើតឡើងជិតមួយសតវត្សរ៍កន្លះមកហើយ ដើម្បីថែរក្សាឱ្យបាននូវចំណាត់ការមនុស្សធម៌ក្នុងភ្លើងសង្គ្រាម ។

អាយ.ស៊ី.អរ.ស៊ី ជា:

- អង្គការមនុស្សធម៌ដែលមានដើមកំណើតនៅប្រទេសស្វ៊ីស មានប្រតិបត្តិការទូទាំងសកល និង មានឋានៈស្របតាមច្បាប់អន្តរជាតិ ។
- អង្គការអព្យាក្រិត មិនលំអៀង និង ឯករាជ្យ ធ្វើការក្នុងពេលមានជម្លោះប្រដាប់អាវុធ និង ក្នុងស្ថានការណ៍នៃអំពើហិង្សាផ្សេងៗ ។
- ឆ្មាំការពារច្បាប់មនុស្សធម៌អន្តរជាតិ ( អនុសញ្ញាហ្សឺណែវ ) ។
- អង្គការស្ថាបនិកនៃចលនាអន្តរជាតិកាកបាទក្រហម និង អឌ្ឍចន្ទក្រហម ( ឆ្នាំ១៨៦៣ )

# ICRC តើ អាយ.ស៊ី.អរ.ស៊ី បំពេញការងារយ៉ាងដូចម្ដេច?



បណ្តុះបណ្តាលអ្នកឯកទេសនៃប្រទេសដែលខ្លួនបំពេញការងារ ស្តីពីបច្ចេកទេសសល្យសាស្ត្រ ( វះកាត់ ) គឺជាការប្តេជ្ញាចិត្តដ៏ឥតងាករេរបស់ អាយ.ស៊ី.អរ.ស៊ី ។

- គោលការណ៍របស់កាកបាទក្រហម និង អឌ្ឍចន្ទក្រហម ស្តីពី អព្យាក្រិតភាព ភាពមិនលំអៀង និង ឯករាជ្យភាព ធ្វើឱ្យ អាយ.ស៊ី.អរ.ស៊ី អាចការពារ និង ជួយជនរងគ្រោះដោយសារជម្លោះនៃភាគីទាំងសង្ខាង ។
- អាយ.ស៊ី.អរ.ស៊ី បន្តការចរចាជាមួយគ្រប់ភាគីទាំងអស់ និង ដើរតួនាទីជាអន្តរការី អព្យាក្រិតដ៏សំខាន់ ក្នុងកិច្ចការពារសិទ្ធិរបស់ឈ្លើយសឹក ឬ សុវត្ថិភាពរបស់ចំណាប់ខ្មាំង ។
- យ.ស៊ី.អរ.ស៊ី សហការជាមួយសមាគមជាតិ កាកបាទក្រហម និង អឌ្ឍចន្ទក្រហម ក៏ដូចជាអង្គការមនុស្សធម៌តែមួយ និង សហព័ន្ធអន្តរជាតិផងដែរ ។
- សកម្មភាពរបស់ អាយ.ស៊ី.អរ.ស៊ី បានទទួលការឧបត្ថម្ភទាំងស្រុងតាមរយៈការបរិច្ចាគដោយស្ម័គ្រចិត្ត មួយភាគធំ ពីសំណាក់រដ្ឋាភិបាល និង សមាគមជាតិទាំងមូល ។

# ICRC តើ អាយ.ស៊ី.អរ.ស៊ី មានទីតាំងនៅទីណាខ្លះ?



បណ្តាញការិយាល័យរបស់ អាយ.ស៊ី.អរ.ស៊ី តែងប្រែប្រួលទៅតាមការប្តូរផ្លាស់នៃតម្រូវការមនុស្សធម៌ នៅតាមបណ្តាប្រទេស ដែលរងការប៉ះទង្គិច ដោយជម្លោះប្រដាប់អាវុធ និង ស្ថានការណ៍នៃអំពើហិង្សាផ្សេងៗនៅជុំវិញពិភពលោក ។ ឧទាហរ៍ជាក់ស្តែង នៅដើមឆ្នាំ ២០០៣ អាយ.ស៊ី.អរ.ស៊ី មានការិយាល័យចំនួន ១៦៩ កន្លែង ។

- បច្ចុប្បន្ននេះ អាយ.ស៊ី.អរ.ស៊ី មានវត្តមាននៅក្នុងប្រទេសជាង៨០ ក្នុងទ្វីបអាស៊ី អាហ្វ្រិក អាមេរិកខាងជើង អាមេរិកឡាទីន អឺរ៉ុប និង មជ្ឈិមបូពា ។
- អាយ.ស៊ី.អរ.ស៊ី មានបុគ្គលិកជាង ១២.០០០ នាក់ ទូទាំងពិភពលោកដែលភាគច្រើនបំផុត ជាជនជាតិ របស់ប្រទេសដែលខ្លួនកំពុងបំពេញបេស តែម្តង ។
- ទីស្នាក់ការកណ្តាលរបស់ អាយ.ស៊ី.អរ.ស៊ី មានទីតាំងនៅទីក្រុងហ្សឺណែវ ប្រទេសស្វ៊ីស ។
- ទីស្នាក់ការប្រចាំតំបន់របស់ អាយ.ស៊ី.អរ.ស៊ី មានទីតាំងនៅទីក្រុងបាងកក ទទួលបន្ទុកការងារក្នុង ប្រទេសថៃឡង់ដ៏ កម្ពុជា ឡាវ និង វៀតណាម ។